00380677

ឯកសារ: D136/3

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

**ភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 29 / 09 / 2009
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Fuy

**សម្តេចមហាពញាចក្រី ហេង សំរិន**

ប្រធានរដ្ឋសភាជាតិ

រាជធានីភ្នំពេញ

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 29 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Fuy

**សម្តេចជាទីគោរព**

នៅក្នុងក្របខណ្ឌនៃកិច្ចស៊ើបសួរដែលកំពុងដំណើរការប្រឆាំងនឹង នួន ជា អៀង សារី ខៀវ សំផន និងជនដ៏ទៃទៀត អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានទទួលការស្នើសុំពីសំណាក់ក្រុមមេធាវីការពារក្តីមួយក្រុម ឲ្យមានការស្តាប់យកចម្លើយ **សម្តេច** ក្នុងឋានៈជាសាក្សី។

ការស្តាប់យកចម្លើយនេះ អាចនឹងមានប្រយោជន៍ដល់ការលាតត្រដាងពីការពិត ហើយ ត្រូវតែរៀបចំឡើងដោយគោរពតាមបែបបទនីតិវិធីដែលតម្រូវចំពោះសហចៅក្រមស៊ើបអង្កេត (បានន័យថា ធ្វើឡើងនៅក្នុងបរិវេណនៃ អ.វ.ត.ក. និង ជាសម្ងាត់)។ នៅក្នុងគោលបំណងនេះ **សម្តេច** អាចឃើញមានភ្ជាប់មកជាមួយនេះនូវដីកាកោះអញ្ជើញសាក្សីផ្លូវការមួយច្បាប់។ ខ្ញុំ សូមបញ្ជាក់ថាកាលបរិច្ឆេទដែលបានដាក់នៅក្នុងដីកានេះ គ្រាន់តែជាកាលបរិច្ឆេទបឋមប៉ុណ្ណោះ។ ដើម្បីកំណត់យកជាក់លាក់ ឬ កំណត់យកកាលបរិច្ឆេទ

00380678

ឯកសារៈD136/3

ផ្សេងទៀតណាមួយ ក្នុងករណីដែល**សម្តេច**មានធុរៈមិនអាចដកឃ្លាពីការងាររបស់**សម្តេច**បាននាកាលបរិច្ឆេទបឋមដែលបានកំណត់ខាងលើ ក្រឡាបញ្ជីរបស់យើង នឹងធ្វើការទាក់ទងលើកិច្ចការនេះ ជាមួយនឹងលេខាធិការដ្ឋានរបស់**សម្តេច** ក្នុងពេលឆាប់ៗនេះ។

សូម **សម្តេច** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

**សហចៅក្រមស៊ើបអង្កេត**

Marcel Lemonde